Khmer Story Lovers


# បញ្ហាមរណៈ

១២

— ទីតាំងការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៨ ផ្លូវលេខ ២០៥ ជ្រុងលេខ ២៥៤ បឹងកេងកង សង្កាត់លេខ ៤ ក្រុងភ្នំពេញ —


## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ចំណែកចិនមិនហួសប្អូនគុញត្រាន់ផងក៏យបារម្ភផងៗ គាត់ចំប្រយ័ត្នប្រយែងឥតហ៊ានប្រោះឡោយទេ ខ្លាចមាណពលួចវាយប៉ះពាល់គាត់ បង្កើតជាការសាកល្បងកម្លាំងកាត់ ៗ ក្បួនជូនពាសបានញុះញង់គាត់ឲ្យប្រើកែស្នៀតដែលមាណពនេះ ៗ បើគាត់ហ៊ានប្រើស្នៀតផ្សេង, ជួនបាស់ចំអកឲ្យភ្នាម ៗ

ការពីដើរផ្សេងគ្រោងក្នុងពិភពតាគុនហួតចំណាស់នេះចិនមិនហួសប្អូនមិនដែលប្រទះឆាកប្រយុទ្ធបែបនេះឡើយ ៗ បើសុំផុតជាអ្នកក្លាហានល្បីល្បាញដែរ គាត់ដេរឲ្យប្រាសរក្សុះមិនខាន ព្រោះមាណពធ្វើព្រាប់តាមគាត់រហូត ។ ឥឡូវរកពាក្យជាឲ្យខាយមិនបានគាត់ខឹងណាស់ ដេររឿវម្នាក់ឯងស្ទាប់ឥតច្បាស់ឡើយ ៗ

មាណពឥតរវល់សោះ បេះតែសម្លឹងតាចាស់មិនដាក់ភ្នែក, រង់ចាំតែគាត់ប្រើស្នៀតមួយ នឹងកាលធ្វើតាមពាល់តែដូច ៗ គេបង្ហការប្រយុទ្ធចំឡែកនេះបានប្រហែលហុកសិបភ្លើង មាណពប្រមូលកម្លាំងជាតុប្រវឹងទះដៃតាចាស់ពាល់ផង បណ្ដាលឲ្យខាយបេះប្រើកម្លាំងកាន់តែស្លាក់ជនាញទៀង ទះម្ដងៗ លាន់ខ្ទរ ដូចព្យុះសង្ក្រា ៗ ចិនមិនហួសប្អូនលែងហ៊ានប្រហែស ខឹងខ្ញុំណាស់ជាកាលុតលាក់តុងទេដឹង? វាជាអ្នកគុនយមខ្លាំងពូកែណាស់តើ ។


អ្នកប្រែសម្រួល: អ.គីមសាន



តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

«មាតុភូមិ»

ភ្នំពេញ

លេខ ១៩

ប្រយុទ្ធយូរទៅគាត់ចាប់អារម្មណ៍ថាបុកឡើងៗ ហាក់ពុំបានចង់លេងដូចមុន, ព្រោះខ្យល់ដៃមាណព ខ្លាំងក្លាពេក, បើអ្នកកម្លោះធ្វើតពេលវាយលុកប្រហែលគាត់ចាញ់ម្ដងទៀតហើយ ។ ទីបំផុត ទីងមិនហួសបួនបែកប្រាជ្ញាចាប់ផ្ដើមបង្វិលដៃពុះឡើងពីរបីដងប្រុងបញ្ចេញស្នៀត «ឆ្វេងផងស្ដាំផង» ស្នៀតនេះសំខាន់ត្រង់អ្នកសង្កេតអាចវាយស្ដាំក៏បានឆ្វេងក៏បាន ។ ទីងមិនហួសបួនក្រេកអរដោយនឹក ថាអាល្អិតធ្វើក្រាប់យើងលែងកើតហើយ !

វិមន ! ស៊ីផានធ្វើភ្នែកស្ញឹ ស្រែកយ៉ាងរហ័ស :

- នែលោកតាវាយខាងណាហ្នឹង ? ឆ្វេងឬស្ដាំ ?

ទីងមិនហួសបួនសើចក្អាកក្អាយ :

- អើ, ឯងទាយមើលរ៉ុយ ! ឆ្វេងឬស្ដាំ ?

គាត់នៅតែធ្វើដៃញ័រខពីមុខបក្ការលឲ្យស៊ីផានក៏យកតែលើកដៃទាំងពីរគ្រវីគ្រវាត់ដៃ, ប្រុងចាំ បោតដៃគាត់តាមបណ្ដាំដូនចាស់ ។ ទីងមិនហួសបួនឃើញមាណពបញ្ចេញកាយវិការយ៉ាងល្ងង់ខ្លៅ បែបនេះក៏ខ្វល់ខ្វាយយ៉ាងខ្លាំងមិនដឹងវាយខាងណា យកជ័យជំនះបាន, កុំឲ្យមាណពដាក់ដៃមកទាន់ ? បើប្រកួតកម្លាំងធាតុជាមួយវាយើងចប់មិនបានដាច់ខាត ។

ក្នុងគ្រាកាសន្ធនេះ ទីងមិនហួសបួននឹកឃើញឧបាយមួយ ក៏លើកដៃទាំងពីរផ្ទុកក្បាលទះ ទៅលើតាមស្នៀត «ដៃពីរទម្រេមេឃ» សម្រាប់វាយសងនៅឱកាសណាដែលសត្រូវសង្គ្រុបពីលើ ។ ពេលនេះគ្មាននរណាគោតសង្គ្រុបនរណាសោះ ឃើញថាប្រើស្នៀតនេះឥតបានការទេ ។ ក៏ព្រោះ ដោយហេតុមាណពធ្វើតាមគាត់ដោយចិត្ត ទើបគាត់ចង់បញ្ជាក់មើលតើអាអស្សែមជំគាត់ល្ងង់ខ្លៅមែនឬ យ៉ាងណា ?

តាចាស់ទះវូទៅលើ, ស៊ីផានមិនយល់សោះ ទះរ៉ូវៗបញ្ចេញខ្យល់រំពាត់ទទេ ក៏ឥតមាន ត្រូវនរណាសោះ ។ អ្នកទាំងពីរមើលមុខគ្នាឡិងឡង់, ទីងមិនហួសបួនទ្រាំមិនបានផ្ទុះសំណើច ហាសៗ... ស៊ីផានឃើញតាចាស់គ្មានគំនិតអាក្រក់ក៏សើចតបវិញ ។ នារីឈ្មោះអាស៊ីវអង្គុយផ្អែក នឹងជញ្ជាំងទូកញញឹមស្រស់ ។ មានតែដូនចាស់ទេដែលស្រែកជៀល :

- ក្បាលកញ្ចាស់ហើយមិនចេះខ្មាសគេទេ ! វាយមិនឈ្នះក្មេង បែរជាប្រើកលល្បិចបោកបញ្ឆោត វាទៅវិញ !

ទីនមិនហ្វូសប្អូនមិនដែលរីករាយសប្បាយដូចថ្ងៃនេះទេ ។ គាត់សប្បាយចិត្តដោយរំភើបញាប់ញ័យ បៀសផុតពីការប្រកួតកម្លាំងធាតុជាមួយស៊ីផធាន ។ គាត់សើចដាក់ឥតរវល់ស្ដាប់ពាក្យបំអកឡកឡឺយរបស់ដូនចាស់ឡើយ ។ លុះសើចឆ្អែតទើបគាត់ពោល :

– យើងមិនរកប្រហក់នេះគ្មានគំនុំគុំគួនរឿងទេ , បំបាច់ប្រើកម្លាំងធាតុសម្លាប់វាធ្វើអី ?

ដូនចាស់ហៀបឆ្លើយតបស្រាប់តែទូកយោងយោងបក់ចូលស្ទឹងមួយទឹកហូរខ្លួលខ្លាញ់ ។

ទីនមិនហ្វូសប្អូនសើចញាក់ញាយ :

– ដល់កោះខ្យងទៀតហើយអាល្អយ ។ នាំទៅស្រីឯងទៀងលេងពីរបីថ្ងៃណា ។ រកអខ្យបង់កំពៅដែរ ។

ដូនចាស់ប្រែទឹកមុខពោលទាំងញញើញញ័រ:

– មិនទៅទេ ។ ទេ ។ តោះស្លាប់ក៏យើងមិនជាន់កោះខ្មោចរបស់កញ្ចាស់ឯងដែរ ។

– យីអើ ។ ទៅលេងពីរបីថ្ងៃមានចាស់អី ?

គ្រង់នេះទឹកហូរវិលវល់យ៉ាងបំភ្លេកបែកសំពោងខ្វាតពេញទូកតូច ។ ស៊ីផធានសម្លឹងតាម ទីនមិនហ្វូសប្អូនឃើញកោះមួយទៀតស្រឆាត់ផុះប៉ុចមកមែន ។ មើលពីចម្ងាយឃើញកងដូចខ្យង ឆាយនឹកថាពិតជាកោះខ្យងទៀតហ្នឹងហើយ ។

ទីនមិនហ្វូសប្អូនប្រាប់តាចាស់កាន់ចង្កូតថា :

–កាច់ចង្កូតទូកសំដៅកោះនោះភ្លាមទៀង ។ តាចាស់ឆ្លើយបាទ ។ ទីនមិនហ្វូសប្អូនលើក យុថ្កាជាស្រេច រង់ចាំតួនទូកទៅជិតដល់និងអាលបោះទៅ ។

ស៊ីផធានពោលទាំងឆ្ងល់ :

– លោកតា, បើលោកយាយមិនចង់ទៅលេងផ្ទះលោកតាទេ, ម៉េចក៏...ម៉េចក៏...

ពោលមិនទាន់ចប់ផង ស្រាប់តែឆាយឃើញដូនចាស់ចាប់ដៃចៅស្រីលោតប្រុងចុះទឹកទន្លេ ។ ទីនមិនហ្វូសប្អូនស្រែកព៉សស្ទុះមកប្រុងឃាត់តែមិនទាន់ ។ ជីដូនមិងចៅលោតក្នុងបែកទឹកសំពោង ស៊ីផធានភ័យណាស់កញ្ឆក់បានក្ដារមួយបន្ទះបោះទៅក្នុងទឹកលោតតាមក្រោយដែរ ។ ដោយហេតុ ឆាយធាក់ខ្លាំងពេកទូកតូចយ៉េងយ៉ោងស្ទើរលិចតែឆាយបានទៅដល់ដូនចាស់និងចៅស្រីគាត់ស្រេច ។

មាណពមិនចេះហែលទឹកសោះលិចក្នុងទៅត្រូវរលកវាយផ្ទប់ផឹកទឹកក្អឹក ៗ ។ តោះបីយ៉ាងនេះក្ដី

នាយចង់ជួយយកកាសកជូនចាស់ គិត ‹‹កាស៊ីរ៉›› ពពាស់ ក៏ទំរោករបង្គុះក្ដារដៃម្ខាង ខំចាប់ស្រវ៉ាសក់ក្បាលជូនចាស់ដោយដៃម្ខាង ។ ទឹកហូរម្ដងទៀតនាំអ្នកទាំងពីរទៅមុខបន្តិច , ជូនចាស់ទប់ទៅស្រីផាប់ , ស៊ីផឹងផឹកទឹកវក្តុតវិលមុខព្រិលភ្នែកមើលអ្វីលែងឃើញ ។ នាយបណ្ដោយតាមយថាកម្ម ស្រាប់តែឈើគ្រលីបង្គុះខ្នាក ។, គឺនាយអណ្ដែតមកប៉ះដុំថ្មយ៉ាងធំ ។ មាណពវែងភ័យប្រឹងទាក់ជើងរបស់ចំហឹង ទើបប៉ះដីវិញ ។ នាយអរកើតងើបមុខមើលឃើញផ្សែងខ្មួលខ្មាញ់ខ្មៅងងឹតហាក់ចេញមកពីដើមឈើប្រូងប្រាង ។

នាយមិនពិចារណាច្រើនទេប្រញាប់អូសដៃជូនចាស់ឡើងគោក ។ សំណាងល្អដោយលោកយាយគុបទៅស្រីផាប់ងវែល តែមិនដឹងជារស់ឬស្លាប់ ។ មាណពតូសពីជូនដិនទៅសំណៅព្រៃដែលមានផ្សែងខ្មៅ ដល់ដីស្ងួតស្រាប់តែជូនចាស់ស្រែកថា :

- ការចោរគេបោតម៉េចហ៊ានទាញសក់ក្បាលយើង ?

មាណពស្រឡាំងកាំង :

- បាទ , សូមលោកយាយអភ័យទោស ។

ជូនចាស់គំហកទៀត:

- នៅក្នុងទឹកឯងចាប់ទាញសក់យើងឈឺណាស់ !

ពោលបប់ជូនចាស់ក្អួតវឹកៗ . . . នារីពោលថា :

- យាយអើយ, បើកុំតែបានលោកបងខាងណោះជួយ , យាយមិនទៅឥតបេះដៅហាលទឹកប្រហែល . . .

នាងពោលបានតែប៉ុណ្ណោះក៏ក្អួតវឹកៗបញ្ចេញសុទ្ធតែទឹកមកដៃ ។

ជូនចាស់សួរ:

- បើអីចឹងអាប្រុសនេះមានគុណលើយើងទាំងពីរមែនទេ ? ញ្ញើយ, អំពើត្រាំគួរដែលកន្លងហើយយើងមិនប្រកាន់ទេ

នារីញញឹមស្រស់ :

- ក្នុងពេលជួយសង្គ្រោះជីវិតមនុស្សប្អូន ។ យើងនឹកអ្វីមិនទាន់ទេ ... លោកបង ... ខ្ញុំសូមថ្លែងអំណរគុណ ។

Khmer Story Lovers



នារីព្រមទាំងជូនចាស់នៅក្បែរស៊ុំផងានណាស់, ផង្អើមគឹគិតគ្នា, មុខមាត់ពីផិតគ្នា ។ ពេល
ជូនចាស់និងនាងក្រមុំព្រួសចំក់រក ១ មកនោះខោអាវមាណពដែលទទឹកស្រាប់ កំទទួលកំសួតទឹកពី
ក្នុងទៀតបណ្ដាលឲ្យ "អាស៊ីវ" អៀនខ្មាសជាពន់ពេក និយាយផតហ៊ានមើលមុខមាណពទេខ្លាច
ឲ្យភ្នែកប៉ះគ្នា ។

ទីបំផុតជូនចាស់ពោល :

-ឯងជាក់យើងចុះបានហើយ ។ នេះប្រហែលជាកោះផ្សេងទៀតហើយ, នៅមិនឆ្ងាយពីកោះ
ឫងទៀតទេ ។ យើងត្រូវប្រយ័ត្នឲ្យមែនទែន, អាកញ្ចាស់ហ្នឹងមិននៅស្ងៀមទេ ។

មាណពឆ្លើយបាទ ១ ប្រុងទម្លាក់ជីជូននិងទៅចុះដីស្រាប់តែឮសម្លេងពីក្រោយខ្នងល្វើយ ១ :

-អានេះប្រហែលមិនស្លាប់ទេ, យើងត្រូវរកវាទាល់តែឃើញ ។

មាណពភ្ញាក់ព្រើត ពោលតិច ១ :

– ទីងមិនហួសប្អូនដេញតាមយើងហើយ ។

ពោលចប់នាយអូសដៃជូនចាស់ និង នាងក្រមុំទៅពួនសម្ងំក្នុងគុម្ពោតព្រៃ ឥតហ៊ានកម្រើកឡើយ ។
គេឮសូរជើងមនុស្សដើរជាន់ស្លឹកឈើប្រោក ១ គឺតាចាស់ម្នាក់និងនារីជីកេ្មងមួយរូប ។ គ្រាន់តែ
ឃើញភ្លាមស៊ុំផងានគិតភ័យជាងកាលនាយពោលថាទីងមិនហួសប្អូនដេញតាមទៅទៀត ។ ត្បិតពីរ
នាក់នេះគ្មាននរណាក្រៅពីទីងមិនហួសបី និង ទីងគុងទៅស្រីប៉ុលប៉ូចរបស់គាត់ឡើយ ។

តាចាស់ត្រកូលទីងទាំងពីរជាបងប្អូនបង្កើតលើសខ្វះគ្នាតែមួយឆ្នាំប៉ុណ្ណោះ ម្ល៉ោះហើយសំដីសំ-
ដៅប្រហាក់ប្រហែលគ្នាទើបមាណពច្រឡំ ។ ពេលនេះនាយពោលញីមាត់ប្រាប់ជូនចាស់ :

– នេះគឺលោកតាទីងមិនហួសបីទេ, លោកយាយ ។

ជូនចាស់សួរ:

– ហេតុអ្វីឯងភ័យសម្បើមម្ល៉េះ ? ក្រែងទៅប្រើគេបង្ក្រាត់ស្លៀតចាប់ខ្ញុំដល់ឯងឬ ?

– ខ្ញុំខ្លាចណាស់ព្រោះលោកតាចង់សម្លាប់ខ្ញុំ, ហើយទីង១ គុង១ ថាខ្ញុំមិនស្លាប់បន្ដាប់នាងបានជាចង់
ខ្ញុំដួចនំអន្សមហោះចូលទូកលោកយាយនោះណា ! បើគ្មានទូកលោកយាយខ្ញុំ ... ខ្ញុំ ... ប្រហែល ...

ជូនចាស់សើច :

-បើយាយមិនទៅត្រង់នោះឯងក្លាយទៅជាអណ្ដើកឬកន្ធាយឬជាចំណីត្រីហើយមែនទេ ?

មាណពងក់ក្បាលឆ្លើយបាទៗ, នឹកដល់ការដែលចិនតុងចងនាយកប៉ុស៊ីបផ្ទុំទាល់តែរឹងស្អុកដូចដុំឈើ នាយព្រឺសម្បុរតែក្ដុកមិនអស់ភ័យសោះ ។ នាយពោលតិចៗ :

–លោកយាយអើយលោកយាយ, គេដើររកខ្ញុំហើយ! បើគេឃើញមុននេះខ្ញុំប្រហែល... ប្រហែលគ្មានសំណាងរស់រួចទេ ។

ដូនចាស់គំហកខ្លាំងៗ :

– ហ៊ឹះ ! បើយើងគ្មានរបួសយើងមិនខ្លាចពួកនេះទេ ។ ឯងទៅហៅគេមកមើល, នរណាមួយហ៊ានប៉ះពាល់ឯង ?

ដូនចាស់អង់អាចក្លាហានណាស់, មានរបួសប៉ុណ្ណោះហើយនៅរឹតក្អេងក្អាងទៀត ។ នាំ ផាទៅអង្វរ :

– លោកយាយ, ពេលនេះមិនទាន់មានកម្លាំងស្រួលបួល គួរគេចពីបន្តួចគ្រកុលចិនសិនទៅ ចាំកាលណាបានកម្លាំងបរិបូណ៌សឹមត្រឡប់មកសងសឹក ។

ដូនចាស់តូចចិត្តណាស់ពោលទាំងគំហក :

– មុននេះដូនឯងស៊ីយកតែមុខ ! ស៊ីសាវណ្ណញញាប់ជើរធ្វើក្រោមកក្រិតគុនមួយជាតិហើយ មិនដែលចំអក់ចិត្តសង្កត់ចិត្តដូចជាមានកម្លាំងដូចថ្ងៃនេះទេ ។ ហ៊ឹះ ! និយាយទៅនិយាយមក ខុសពីកេរ្តិ៍ប្រាជ្ញនិងកេរ្តិ៍ញ្ញាស់ទាំងអស់ ។

– លោកយាយកុំរំពុករឿងចាស់ធ្វើអី, យើងមានគ្រោះថ្នាក់ដូចគ្នាគួរសម្រួលដើម្បីសំរកកម្លាំងវិញ លោកយាយព្រួយចិត្តដូច្នេះនាំមិនស្រួលខ្លួនណា !

ដូនចាស់មិនទាន់សាយកំហឹង ក៏ស្រែកដាក់ទៅ :

– មិនស្រួលខ្លួនក៏យើងមិនខ្លាចដែរ, ថ្ងៃនេះសោយណាស់ ! ដឹកចិត្តទន្ទេញណាងកាងគឹងពោះ ។ ជាតិនេះស៊ីសាវណ្ណយបាត់បង់កិត្តិយសហើយ !

ដូនចាស់ខឹងឡើងនិយាយកាន់តែខ្លាំងឡើង ។ ស៊ីផានខ្លាចចិនមិនហួសបីនិងចិនកុងព្រ ក៏អង្វរ :

– លោកយាយ, សូមកុំខឹងក្រោធពេក, ចាំខ្ញុំ . . . ចាំខ្ញុំជួយបញ្ជូនកម្លាំងជាតុឲ្យបន្តិចទៀត ។ នាយមិនចាំដូនចាស់ឆ្លើយក៏ដាក់ដៃលើខ្នងគាត់បញ្ជូនកម្លាំងជាតុសន្សឹមៗ ... ដូនចាស់ស្ដាយកម្លាំង

ផ្តើមវិលសម្ងំស្រូបធាតុនេះក៏ទទួលយកលែងហាក់ក្តៅហើយទៀត ។ ពេលនោះគាត់នឹកថា:

– អាច្រមក់មានកម្លាំងស្អុកស្អួលណាស់ ហើយបរិសុទ្ធទៀត, ហេតុអ្វីបានមិនរៀនយុទ្ធសិល្បៈ ?

គ្រាន់តែបែកការប្លុកមួយក្តក់សោះ ក្រុងកាត់ពុកបាក់ក្តៅកាយ ។ ក្លាយទៅជាគេគេងបាត់ ។ ដូចជាសម្ងំគេងដើរយ៉ាងស្រួល ទាល់តែស្រាយជីពចរបានមួយ ទើបគាត់ផ្តើមស្ទើរមិនរួច ស្ទុះក្រោកភ្ញាក់សើចដាក់មាណព :

– អរគុណឯងហើយ អាច្រមក់ ។

ស៊ីផានមិនរឺនាក្រេកអរពន់ពេក សួរព្រមគ្នា :

– លោកយាយដើរបានហើយ ឬ ?

យាយស៊ីសាវណ្ណយកតប:

–យាយកំរើកបានតែជើងមួយទេ, នៅសល់ជីពចរច្រើនទៀតស្រាយមិនទាន់បាន ។

–យាយ, ខ្ញុំមិនទាន់ហត់ទេ, គោរពទម្លាយជីពចរទាំងអស់ឲ្យហើយទៅ ។

យាយញញួយជ្រួញចិញ្ចើម:

–ឯងនៅក្មេងមិនដឹងអ្វីទេ យាយស្គាល់ស្អប់គេ ។ បើងងឹងការស៊ីវទំហាត់ «គម្ពីរបិសាច» ទាល់តែមានគ្រោះថ្នាក់បែបហ្នឹង, មិនមែនហៅថាគ្រោះថ្នាក់ធម្មតាទេ ។ ថ្ងៃនេះស្រាយបានមួយទុកដូចជាសំណាងធំហើយណា៎ ! បើនឹងហាមទាយថា មិនអាចស្រាយជីពចរទាំងអស់បានក្នុងថ្ងៃតែមួយទេ ។

ស៊ីផានឆ្លើយដាក់ដុប :

– បាទ ។ ... នេះមកពីខ្ញុំមិនយល់ការ, សូមលោកយាយជួយប្រាប់ផង ។

– អើ ! បើគង់ទំនេរដែល ឯងទៅជួយស្រាយជីពចរជើងកាស៊ីវផង ។

មាណពឆ្លើយបាទ ហើយលើកក្រាហ៍នាងស៊ីវទៅដាក់ឲ្យអង្គុយផ្អែកគល់ឈើ ទើបដាក់ដៃសង្កត់ជីពចរលើខ្នងនាង បញ្ចូលកម្លាំងធាតុបន្តិចម្តងៗ ដូចដែលបានព្យាបាលជីពចរឲ្យដូនចាស់ ។ តែនាងក្រមុំនេះខ្សោយជាងដូនចាស់ឆ្ងាយណាស់ ទាល់តែចំណាយពេលយូរជាងបី-បួនដង ទើបនាងទំគ្រងក្រោកឈរបាន ហើយពោលតិចៗសឹងស្តាប់មិនឮថា:

– អរគុណលោកបងហើយ ។ លោកយាយ, បើនឹងមិនដឹងលោកបងនេះឈ្មោះអ្វីទេ,

ពិបាកហៅគាត់ហើយដូចជាមិនសមទេឬលោកយាយ ?

នាងចង់សួរឈ្មោះគេ តែនាងអៀនខ្មាសច្រើន ទើបពោលទៅកាន់ជីដូនវិញ ។ មាណពនឹកក្នុងចិត្តថា : យើងឈ្មោះអ្វីដែរ ?

យាយសាវល្អញាក់សួរភ្លាម :

-អីអាអន្សមធំ, ចៅយើងសួរឯងឈ្មោះអី ?

មាណពអេះអុញ :

-ខ្ញុំ ... ខ្ញុំឥតដឹងដែរយាយ ។ ម៉ែខ្ញុំហៅថា ... ក្តែ .. ក្តែ ...

នាយចង់ប្រាប់ដូចមុនៗថាឈ្មោះក្តែឥតពូជតែឥឡូវនាយយល់ហើយថានេះមិនសមឈ្មោះមនុស្សទេ មិនគួរប្រាប់នារីសុភាពកបសាឈ្មោះអាស៊ីវនេះឡើយ ។

នាយពោលបន្ត :

- មានគេប្រចាំខ្ញុំថា ជាមនុស្សម្នាក់, តាមពិតខ្ញុំមិនមែនអ្នកនោះទេ... ខ្ញុំជាអ្នកណា ? ខ្លួនខ្ញុំក៏មិនដឹងដែរ ។

យាយសាវល្អយកុញច្រានណាស់គំហកកាត់:

- បើមិនប្រាប់ហ៊ីចុះ ! កុំរញ៉ូរញ៉ាំច្រើនពេក !

អាស៊ីវពោលបន្ត:

- បើគេមិនចង់ប្រាប់យើង, កុំដឹកសួរពេក, ក្រែងគេមានកង្វល់ផ្ទាំងអីណា៎យាយ ។ ហៅឈ្មោះឬមិនហៅឈ្មោះឥតចាស់ខុសទេ យាយ ឲ្យតែយើងនឹកគុណគេរហូតទៅបានហើយ ។

ស៊ីផានប្រញាប់តបថា:

- មិនមែនទេ, អ្នកនាងយល់ច្រឡំហើយ ។ ខ្ញុំមិនជំកបព្រោះខ្ញុំគ្មានឈ្មោះនឹងគេណា៎ ! ឈ្មោះខ្ញុំអាក្រក់ស្អប់ណាស់ ។

ដូនចាស់ត្រកូលស៊ីតប :

- អាក្រក់ស្អប់ល្អស្អាប់យ៉ាងម៉េច ? អាក្រក់ជាងឈ្មោះអាអន្សមធំឬ ? បើឯងមិនប្រាប់ យើងនាំគ្នាហៅអាអន្សមធំរហូតណា៎ !

មាណពនឹកថា «អន្សមធំ» ល្អគ្រាន់បើជាងក្តែឥតពូជដែរ ។ នាយស្ញើចតប :

– ហៅតាមឲ្យមកកំបាននៅវេ, ចិកពាក់ស្លាប់ទៅលោកយាយ ។

កាស៊ីវឃើញកម្លោះស្លូតបូតមិនចេះនិយាយ គាត់ក៏តែពិបាកចិត្ត គោលទៅកាន់ផ្ងួនថា :

–លោកយាយ, កុំនិយាយលេងជាមួយគាត់ច្រើនពេក, លោកបងខាងកោះគុ ...

មាណពញញឹមគោលគាត់:

–មិនទាស់អីទេ ។ សូមកុំឲ្យតែចិនមិនហួសបីនឹងចិនតុងរកខ្ញុំឃើញនោះជាការប្រពៃហើយ សូមលោកយាយនិងអ្នកនាងសំរាកកន្លែងហ្នឹងចុះ ខ្ញុំទៅរកមើលក្រែងមានអ្វីបរិភោគបាន ។

ផ្ងួនបាស់ឆ្លើយ:

–នៅលើកោះផ្សែងខ្មៅនេះ មានផ្លែឈើក្រហមច្រើនណាស់ ។ ផល់ផ្លូវខ្ញុំហើយ ឯងទៅបេះខ្លះមក! នៅតាមជាយកោះក៏មានត្រីនិងក្តាមច្រើនដែរ, ឯងទៅចាប់មកដុតស៊ី ។

មាណពនឹកក្បាលដើរលេង ១ ចេញទៅខាងជើងកោះនៃក្រកូលចិនឃើញ ។ ចេញផុតគុម្ពោតព្រៃនេះទៅ នាយឃើញឈើធំ ១ ដុះតាមជំរាលភ្នំផ្លែទុំក្រហមច្រាល ។

## វគ្គទី ១៩

## សិស្សច្បងនៃក្រុមព្រះអាទិត្យ

ស៊ីផានដើរទៅក្រោមដើមឈើចាប់មែកអង្រួនច្រាវ ១ ៗ ហេតុតែកម្លាំងនាយច្រើនលើសលុបទើបផ្លែឈើទុំធ្លាក់ពុយ ។ នាយលោតក្រវាត់ដៃជាយអាវជាថង់ល្បោ រួចតែទៅកាន់គុម្ពោតព្រៃវិញ ។ ផ្ងួនបាស់មិនទៅប្រើកាចបើបោនមែន តែជីតចរលើដៃចាំនអស់ស្រាយមិនទាន់បានទេ ។ យាយសាវល្អួយបន្ទំលើកដៃទទួលផ្លែឈើទុំពិសាដោយលំបាក, កាស៊ីវក៏កើតមិនរួចសោះ ។ ក្នុងករណីនេះមាណពត្រូវបកផ្លែឈើបញ្ចុកផ្ងួនបាស់ផង, បញ្ចុកនាងក្រមុំជាទៅផង ។

កាស៊ីវជាស្រីក្រមុំអៀនខ្មាសម្នាក់ ឲ្យគេបកផ្លែឈើបញ្ចុកដូច្នេះ មុខនាងឡើងពណ៌ក្រហមជាងផ្លែឈើទុំដោយភាពការអៀនខ្មាស ប៉ុន្តែគេដាក់ដល់មាត់ហើយ នាងបដិសេធមិនបានក៏បាមាត់ចំពោះទៅ ។ ដល់មាណពបកសំបកបញ្ចុកមួយទៀត នាងប្រកែកដោយទន់ភ្លន់ :

–សូមលោកបងពិសាមុនចុះ, ចាំខ្ញុំសិន ...

Khmer Story Lovers



យាយសាវណ្ណយពោល :

– នៅខាងលិចឆ្ងាយពីនេះប្រហែលជាងមួយយោជន៍មានភ្នំធំណាស់ ។ ចាំយប់យើងនាំគ្នាទៅសំណាក់ទីនោះកុំឲ្យបងប្អូនខ្មោចមិនហួសប៉ីមិនហួសប្អូនគេត្រួតយើងឃើញ ។

មាណពត្រេកអរណាស់ញញឹមងក់ក្បាលទទួល ។ នាយមិនញញើតទីងមិនហួសប្អូន ដល់ទីងមិនហួសប៉ី និង ទៅស្រីទីង១ ក្មេង១ ទេ ព្រោះតែខាក់នោះចង់សម្លាប់នាយ ។

ឥឡូវឮថា មានគន្លងក្លួននាយត្រេកអរក្រៃលែង ចង់តែឲ្យតែថ្ងៃលិចនឹងគេលនាំគ្នាទៅសំណាក់ ។

សុផាតកាន់ដៃយាយសាវណ្ណយម្ខាង ជួយគ្រាប់គាងក្រមុំម្ខាង ដើរលំពៅទិសខាងលិចតាមផ្លូវតូចៗ ដូនតាស់ប្រហែលជាប៉មកលេងកំសាន្តលើភ្នំនេះ ព្រោះជាស្គាល់ផ្លូវច្បាស់ម្ល៉េះ ។ បានជិតមួយយោជន៍គេមកដល់ជញ្ជាំងភ្នំមួយជួរ ។ យាយសាវណ្ណយប្រាប់មាណពឲ្យបត់ឆ្វេងបត់ស្តាំ រួចមុទក្បាលចូលគុម្ពោតព្រៃស៊ុបទ្រុប ទើបដល់រូងភ្នំ ។

សុផាតពោលសំកាត់ទីនោះស្រេចបាច់ហើយ, យាយសាវណ្ណយផ្តើមវាចា:

– អាអន្សមធំ,យប់នេះងងឹតយាមមាត់រូងណា ! កុំឲ្យប៉ូលេកុងទេ ។

មាណពគ្រវីយបាទ១ ហើយពោលបន្ថ:

– គួរស្តាយណាស់លោកយាយអ្ហ៊ុ ! យើងមិនបានបង្កាត់ភ្លើងបំភ្លឺមេខាកាវឲ្យស្លុត ....

ដូនតាស់ពោលម៉ាត់ៗ:

– ហ្នឹងហើយដែលគេហៅថា ខ្មោចអាក្រក់គ្រប់ល្បែងញោយណា ! ថ្ងៃក្រោយត្រូវតាប់កុលខ្មោចបងប្អូនមិនហួសប៉ី មិនហួសប្អូននេះឲ្យវាចុកចាប់ជាងយើងជប់ជង !

ស្មុគស្មាញអ្នកតាំងបីក្រោកបាតនិទ្រាដោយសុខសាន្ត ។ គេបរិភោគផ្លែឈើ ទុំក្រហម ទៀត បន្ទាប់ពីនោះសុផាតបញ្ជូនកម្លាំងជាតុព្យាបាលជីតបរឲ្យដូនជីងទៅបានម្នាក់មួយកន្លែងទៀត គាបកុំរើកដៃតាំងពីរបាបដូចនេះ ។

យាយសាវណ្ណយបញ្ចេញយោបល់ :

– ប៉ុណ្ណឹងសិកកុះកោរត្បែតុំ , ប្អូនទៅរកត្រីពិតក្លាយកោរផុតសុំអ្វី? សក់ក្លាប្រហែលល្អជាងផ្លែឈើ ។.

ស៊ីផានញញឹមបន្តិចទើបតប ៖

- ចាប់ក្តាមដាយទេ    ប៉ុន្តែយើងមានស្អីផុតបើបេះបន្ទាត់ភ្លើងមិនកើត ?

- ហ៊ឺះ ! កើតជាប្រុសធំដូចឃ្មោក មើចខ្លាចកកញ្ចាស់ទ័ពមិនហ៊ានបីខ្ទាំងដៃម៉្លេះ ?

ស៊ីផានគ្រវីក្បាល៖

- មិនត្រឹមតែទ័ពមិនហ៊ានប៉ះទេ, ទ័ព ១ គុណ ១ ក៏ត្រូវលេងជាដាច់ខ្ញុំកាចចាប់ខ្ញុំចងដូចនិអន្សមដែរ ។ បើគេចាប់ខ្ញុំបោះចោលក្នុងទន្លេទៀតច្បាស់ជាវិវរធំហើយ ។

នាងក្រមុំជួយអង្វរ៖

- លោកយាយ,    លោកបងនេះនិយាយសមហេតុសមផលប៉ុណ្ណឹងដែរ,    ត្រូវតែតួតបំប្រាយជីតបអស់សិន ។    កាលណាលោកយាយមានកម្លាំងពលំដូចដើម,    យើងលែងខ្លាចទ័ពមិនហ៊ានបី មិនហ៊ានបួនទៀតហើយ ។

- ហ៊ឺះ !    ឯងនិយាយដូចប្រួលផល់ហើយហ្ន៎ !    ចង់មានកម្លាំងដូចដើមមិនបែបពីយទេ, ហោចណាស់ក៏ដប់ថ្ងៃដែរ    ទើបប្រោយជីតបទាំងអស់រួច ។    បើត្រូវការកម្លាំងដូចដើមគោរពនិងចាំប្រាំបីខែឬមួយឆ្នាំឯណោះ ។    យើងគិតស៊ីតែផ្លែឈើដូច្នេះកើតដែរឬ ?    ម្យ៉ាងទៀតផ្លែឈើអស់នេះមិនគង់យូរទេ,    ពីរបីថ្ងៃទៀតវាផ្អុះស្អុយអស់ហើយ ។

ស៊ីផានគិតបន្តិចទើបឆ្លើយ ៖

-រឿងហ្នឹងយាយកុំព្រួយ,    ចាំខ្ញុំទៅបេះផ្លែពេលីត្បូងណាខ្លះមកបកហាលថ្ងៃទុកស៊ីយូរ ។ កម្មោះនេះយល់ថាការរស់នៅក្នុងលោកពិបាកហើយស្មុគស្មាញណាស់,បើរស់លើកោះនេះរហូតប្រហែលគ្មានបញ្ហាដោះស្រាយទេ ។ ចំណែកយាយសាវក្លួយគោលបន្ទោសថាយថា ៖

- ឯងសុខចិត្តធ្វើអណ្តើកលាក់ក្បាលក្នុងស្នូកបាន    តែយើងធ្វើមិនកើតទេ    ព្រោះមួយថ្ងៃ ឬពីរថ្ងៃទៀតកញ្ចាស់ទ័ពតែកេយើងឃើញហើយ !    ឯងធ្វើអណ្តើកក៏មិនសុខដែរ ។    អាអន្សមធំឯង មើចក៏ខុសគេម៉្លេះ ?    មានតែកម្លាំងពិតាកុប្រៀវស្រះតែមិនចេះប្រុងសិល្បៈអ្វីសោះ !

ស៊ីផានជាក់មុខស្រប់ ៖

- នេះមកពីគ្មានអ្នកណាបង្ហាត់ខ្ញុំលោកយាយអើយ,    ខ្ញុំចេះតែស្លៀតបាប់ញាំចាំងដប់ប្រាំបីដែលទ័ព១ គុណ១ បង្រៀននោះឯង    ធ្វើមើចកោចឈ្នះគេ ?    បើនិយាយពីគុណដែលលោកតាទ័ព

មិនហួសបួនបញ្ជាក់នោះ ក៏គ្មានប្រយោជន៍អីប៉ុន្មានដែរ...

ស្រាប់តែនាងក្រមុំពោលថា :

-លោកយាយអើ ! ម៉េចមិនជួយបញ្ជាក់គាត់ខ្លះផង ? បើគាត់ចេះយុទ្ធសិល្បៈលោកយាយ, លោកយាយឲ្យគាត់វាយប្រហារទីងមិនហួសបួនក្បាច់ជាការស្រេចហើយ, លោកយាយមិនបាច់ទៀតទេ ។

យាយសាវណ្ណយបើកភ្នែកសម្លឹងស៊ីផានផងត្រង់ ។ មិនយូរប៉ុន្មានពន្លឺភ្នែកគាត់បញ្ចេញស្លឹកាចសាហាវឡើងៗ, ដៃចាំងតែញ័រញ៉ាក់ហាក់បងស្លុះទៅចាក់គេស៊ីផានចាំងរស់ ។ មាណពក៏យំណាស់ផកខ្លួនថយក្រោយជាបន្ទាន់:

- លោកយាយ ... លោក ... លោកយាយ !

ស៊ីសាវណ្ណយស្រែកសន្ធាប់:

- ណាស៊ីវ ! ទៅមើលឲ្យមែនទែនមើល ! ដូចឬមិនដូច ?

អាស៊ីវបើកភ្នែកផងសម្លឹងមាណពមួយសន្ទុះ តែពន្លឺភ្នែកនាងមិនកាចសាហាវដូចជីដូនទេ ។ នាងតបដោយសុភាព:

-មុខគាត់ប្រហាក់ប្រហែលមែន, តែ ... មិនមែនគាត់ទេ ។ គាត់ ... គាត់គ្មានសន្ដានចិត្តស្លូតត្រង់ដូចលោកបងនេះមួយចំណិតតូចទេលោកយាយ ...

ពន្លឺភ្នែកយាយសាវណ្ណយលែងសាហាវដូចមុន ។ គាត់ត្រហឹម រួចពោល:

-មិនមែនវាទេ ។ ប៉ុន្តែមុខមាត់ដូចគ្នាពេក យាយមិនត្រូវបញ្ជាក់វាឡើយ ។

ស៊ីផានញាក់ញ័រគំនិតភ័យ : ។ ! ម្ដងហាស់នេះសង្ស័យយើងជាស៊ីផានទៀតហើយ ! នាយក្រុមស៊ីអ៊ីគេក្លីងមានសត្រូវច្រើនណាស់, អ្នកណាក៏ស្អប់គាត់ដែរ ។ បើលោកការយើងជួបគេយើងច្បាស់ជាជួយពន្យល់ពីការនាំឲ្យគេយល់ច្រឡំខុស ។

ពេលនោះលោកយាយសាវណ្ណយសួរ :

- ឯងមានត្រកូលស៊ីឬ ?

មាណពត្រវីក្បាល :

- មិនមែនទេ ។ មានគេប្រាប់ខ្ញុំថានាយក្រុមឈានល្បួត្រកូលស៊ីដែរ, តែខ្ញុំមិនមែននាយក្រុមរូបនោះទេ, និយាយយ៉ាងណាក៏គ្មានអ្នកណាជឿខ្ញុំ, ពិបាកណាស់ ។

អាស៊ីវពោលតិចៗ :

– ខ្ញុំជឿលោកបងថានិយាយពាក្យពិត ។

មាណពត្រេកអរណាស់ពោលដោយរំភើប :

– អ្នកនាងជឿសំដីខ្ញុំឬ ? ៗ ! ... ខ្ញុំ ... បានតែអ្នកនាងម្នាក់គត់ដែលជឿខ្ញុំ ។

– លោកបងជាមនុស្សល្អ ... គេជាមនុស្សកាច ។ អ្នកទាំងពីរខុសគ្នាឆ្ងាយណាស់ ។

មាណពត្រេកអរផុតឧបមា ប្រៀបដូចអ្នកជាប់ចោទដែលចៅក្រមការី ការពារខ្លួនបានបាត់ផុតទុក្ខទោស ។ នាយចាប់ដៃនាងក្រមុំប្រញាប់យ៉ាងរំភើប ពោលៈ

– អរគុណអ្នកនាងច្រើន ។

ច្រើនខែថ្ងៃហើយ ដែលអ្នកផងតែងយល់ច្រឡំមិនទាំងនាយថា ជាមេក្រុមស៊ីកេប្រវ័ញ្ចមិនបាន ។ ពេលនេះបានអាស៊ីវបេះស្គាល់ការពិតដូច្នេះ នាយសែនរីករាយ, ពោលអរគុណញាប់មាត់ ។ មាណពសប្បាយហួសប្រមាណ ដួងចិត្តរំជួលញ័រញាក់ត្រជាក់អង្គប្រាណបណ្ដាលឲ្យទឹកភ្នែកហូរធ្លាក់តក់ៗ លើដៃដ៏ទន់ខ្ចីល្អល្អក់នៃនាងកញ្ញាចាំងមិនដឹងខ្លួន ។ នាងក្រមុំភ្ញាសក្រហមមុខឆាំង តែមិនដាច់ចិត្តដកដៃចេញ ។ យាយស៊ីបំអក :

– មែនគឺមែន! មិនមែនគឺមិនមែន! ធំប៉ុណ្ណឹងហើយនៅយំសោកទៀត ល្អមើលណាស់ឬ ?

យុវបុរសលើកដៃជូតទឹកភ្នែក, ឆ្លើយបាទ ទើបភ្ញាក់ព្រើតដោយដឹងថាខ្លួនកំពុងចាប់ដៃនាងកញ្ញាជាប់ ។ នាយប្រញាប់ពោលថា:

– អត់ទោស! អត់ទោស!

ហើយលែងដៃភ្លាមទើបបន្ត :

– ខ្ញុំ ...ខ្ញុំ...ខ្ញុំ ..ខ្ញុំមិនមែន...ខ្ញុំទៅបេះផ្លែឈើហើយ ។

ពោលរួច, ស្ទុះរត់ចេញទៅក្រៅដោយមិនហ៊ានងាកមើលអាស៊ីវទៀតឡើយ ។ យាយប៉ុរឃើញអ្នកកម្លោះរលះរលាំងភ័យស្ទមិនសមជាម្ល៉េពុក ក៏ងឹកអស់សំណើច ហើយដកដង្ហើមធំ:

– ពិតជាមិនមែន! អាចង្រៃត្រកូលស៊ីនោះមិនបានមួយចំណិតអាខ្មែរធំនេះទេ !

មួយសន្ទុះក្រោយស្នូរប្រាវៗលាន់ឮនៅខាងក្រៅ គឺស៊ីផានរត់ត្រឡប់មកវិញដោយភាំភាំង អន្ទះអន្ទែង ទឹកមុខស្លេកស្លាំងស្ទឹកស្ទុកហាក់ភ័យព្រួយរឿងអ្វីមួយ ។ នាយខ្សាវទាំងរអ្នកអណ្ដើតអណ្ដក:

- វី . . . វីវធំហើយ !

- យ៉ាងម៉េច ? ទីងមិនហួសបីឃើញឯងឬ ?

- មិន . . . មិនមែនទេ ! គឺពួកក្ដុំទឹកកកមកដល់កោះនេះហើយ ! គ្រោះថ្នាក់ធំណាស់ ! . . .

យាយស៊ុនិនកាស៊ីគ្រាន់តែឮឈ្មោះក្ដុំទឹកកក ក៏ប្រែទឹកមុខសម្ងំគ្មាបឆ្ងិចទើបយាយស៊ុំសួរ: « អ្នកណា ? » ។

–គឺប៉ាយវ៉ាន់ដាន និងប្អូនស្រីគ្រូប្អូនដប់នាក់ ។ ពួក . . . ពួកគេតាមកេចាប់ខ្ញុំយកទៅផ្ដន្ទាទោសឯវិមានទឹកកកហើយ !

–ចុះពួកវាឃើញឯងទេ ?

–ទេ ! ពួកគាត់មើលខ្ញុំមិនឃើញទេ ! ប៉ុន្តែខ្ញុំឃើញលោកគ្រូប៉ាយវ៉ាន់ដានកំពុងឈរនិយាយជាមួយលោកតា .... ទីង . . . ទីងមិនហួសប្អូន !

យាយស៊ុជ្រួញចិញ្ចើម សួរបញ្ជាក់ :

–ឯងថាទីងមិនហួសប្អូន ឬទីងមិនហួសបី ?

–គឺទីងមិនហួសប្អូន ! ខ្ញុំឮគាត់និយាយថា បើមិនឃើញសាកសពវណ្ណតទឹកទេ ច្បាស់ជានៅលើកោះនេះហើយ, ពួកគេមកតាមរកខ្ញុំហើយ ខ្ញុំ...ខ្ញុំភ័យណាស់ !

អាស៊ុំវល្លិនលោម :

- លោកគ្រូប៉ាយយល់ច្រឡំលើបងមែនទេ ? បើបងពិតជាមនុស្សត្រឹមត្រូវមែន អាចនិយាយរកសខ្មៅឃើញ កុំព្រួយបារម្ភអី !

ស៊ុផ្ដានភ័យបែកញើសស្រាក់ តបថា:

–និយាយស្ដាប់គ្នាមិនចូលទេ !...

យាយស៊ុពោលកាត់:

–បើនិយាយតាមសម្រួលមិនបាន ត្រូវតែប្រយុទ្ធគ្នា ! ក្នុងលោកនេះមិនមែនមានតែឯងម្នាក់ទេដែលត្រូវគេមួលបង្កាច់នោះ !

–ទេ ! លោកគ្រូប៉ាយជាអ្នកក្លាហាននៃក្រុមក្ដុំទឹកកកមានស្នៀតគុនដាវខ្ពង់ខ្ពស់ណាស់ ខ្ញុំ...ខ្ញុំវាយមិនឈ្នះគាត់ទេ !

–ហ៊ឹះ ! ស្នៀតគុនផាវរបស់ពួកក្ដុំទឹកកកពូកែណ្ណ? តាមយើងមើលទៅ ដូចជាខ្សោយពេកណាស់ មាណពកពៃ :

– មិនមែនទេ ! មិនមែនទេ ! លោកគ្រូប៉ាយមានស្នៀតគុនផាវវិសេសវិសាលកេម្យមកប្រៀបផ្ទឹមពុំបានឡើយ គ្រាន់តែលោសំផ្លៅផាវក៏អាចទុកស្លាមប្រាំមួយកន្លែងលើសសរឬខ្លួនមនុស្សបានដែរ ! យាយជឿទេ ?

ពោលចប់នាយទុនលាត់ជើងខាឲ្យជីដូនជិងទៅមើលស្លាមផាវ ។ ដោយហេតុនាយរស់នៅលើខ្នងក្ដុំតាំងពីតូចទើបពុំសូវចេះច្បាប់ទម្លាប់ហើយមិនចាប់ភ្នកថាអំពើនេះមិនគប្បីចំពោះស្រីគ្រប់ដូចយាយស៊ីឡើយ ។ យាយស៊ីត្រហឹមហ៊ឹះ ! ពោលថា :

– ម៉េចក៏ថាយើងមិនជឿ ? អាស៊ីវប្រុសនៅយើងហាត់គម្ពីរបិសាចបានសម្រេច ក្នុងមួយស្នៀតយើងអាចចាក់សំដៅចំណុចប្រាំពីរកន្លែងដែរមែនទេ ?

អាស៊ីវងក់ក្បាលហើយផងផង្អើមធំយ៉ាងស្រាលសំង ស្តាប់មិនឮ ។ តែយាយស៊ីនិងអ្នកកម្លោះស្តាប់ឮយ៉ាងច្បាស់ គេកាត់យល់ថានាងក្រមុំងក់ក្បាលទទួលថាសំដីយាយស៊ីត្រឹមត្រូវមែនហើយផងផង្អើមធំសំដែងការសោកស្ដាយកំពូលវិជ្ជាដែលមិនបានសម្រេចដូចបំណង ដែលតាំងបានគ្រោះថ្នាក់ដល់ជីដូនជិងទៅទៀត ។ ស៊ីផានសម្រួលបរិយាកាស :

–មានគ្រោះថ្នាក់មួយផងមួយកាលកុំទាន់កាលអស់សង្ឃឹមចាំយាយជិងនាងជាសះស្បើយសឹមហាត់រៀនសាថ្មីម្ដងទៀត !

យាយស៊ីស្រែកតាំងតំហក :

–ហ៊ឹះ! និយាយផ្តាស ! បើយើងអាចហាត់រៀនសាថ្មីម្ដងទៀតបាននោះ មិនបាច់ឯងនិយាយច្រើនទេ !

យុវបុរសនឹកឆ្ងល់នឹងការស្តីបន្ទោសនេះពេកក្រៃង នាយអេះក្បាលមិនចេញស្តី ។ យាយស៊ីមិនទាន់បាត់ខឹង ពោលបន្ត:

– តើយុទ្ធសិល្បៈរបស់ពួកក្ដុំទឹកកកពូកែយ៉ាងណាខ្លះ ? តាមស៊ីសាវណ្ណយយើងយល់ថាគ្មានតម្លៃបន្តិចសោះ ! កញ្ចាស់ប៉ាយជីចាយតាំងខ្លួនជាមេចោរនៅឯក្ដុំទឹកកកគ្មានដឹងខ្យល់អ្វីទេ, នឹកស្មានថាខ្លួនជាកំពូលអ្នកក្លាហាន ! ហ៊ឹះ ! យុទ្ធសិល្បៈគុនកាំបិតនៃក្រុមព្រះអាទិត្យជាសត្រូវទីមួយរបស់វា ! អា

អន្ទ្រមធំឯងដឹងថាក្រុមព្រះអាទិត្យមានតិចយ៉ាងទេ ?

– ខ្ញុំ ... ខ្ញុំមិនដឹងទេ !

–ព្រះអាទិត្យរះ ទឹកកកដែលនៅលើភ្នំនឹងទៅជាយ៉ាងណា ?

– អូ ! ព្រះអាទិត្យរះទឹកកកត្រូវតែរលាយ !

យាយស៊ុំសើចក្អាកក្អាយ:

– ត្រូវមែន ! ព្រះអាទិត្យរះ ទឹកកកធ្លាក់ក្លាយជាទឹក ! ដូច្នេះមានតែយុទ្ធសិល្បៈនៃក្រុមព្រះអាទិត្យទេ ដែលអាចបង្ក្រាបយុទ្ធសិល្បៈក្រុមទឹកកកបាន ! ឲ្យតែពួកសិស្សភ្នំទឹកកកជួបប្រទះនឹងក្រុមព្រះអាទិត្យយើង ត្រូវតែលុតជង្គង់សំពះសុំទុកជីវិត !

ស៊ុំផាន់បានឃើញឥទ្ធិពលនៃស្នៀតគុនវេរបស់ប៉ាយវ៉ាន់ជានជាក់នឹងភ្នែក លុះឮយាយស៊ុំអួតថា យុទ្ធសិល្បៈនៃក្រុមព្រះអាទិត្យរបស់គាត់មានប្រសិទ្ធភាពជាង ក៏កើតក្តីសង្ស័យក្រៃ ៗ នាយជាមនុស្សស្មោះត្រង់មិនចេះលាក់ពុត នឹកឃើញយ៉ាងម៉េចបញ្ចេញទឹកមុខតាមនោះ ជាហេតុធ្វើឲ្យយាយចាស់ចាប់ផ្ដាក់បាន ។ គាត់សួរបញ្ជាក់ :

– ឯងមិនជឿ ឬ?

–កាលលោកគ្រូប៉ាយបានចាប់ចងខ្ញុំដាប់នៅក្នុងរោងកញ្ចាស់ ខ្ញុំឃើញបងប្អូនគាត់ប្រកួតប្រជែងគ្នា ក៏បងចាំបានខ្លះ ខ្ញុំយល់ថា ... យុទ្ធសិល្បៈនៃភ្នំទឹកកកពិតជា ... ពិតជា ...

យាយស៊ុំគំហក: «ពិតជាយ៉ាងម៉េច ?»

– បាទ ! ពិតជាពូកែមែន !

–ឯងមើលបងប្អូនគេប្រកួតគ្នាប្រយោបរៀតបេះដូងទៅ ? ម៉េចកើតជាពូកែ? ឥឡូវឯងសំដែងឲ្យយើងមើលបន្តិចមើល !

–ខ្ញុំហាត់ចេះស្តួចស្តើងណាស់មិនពូកែដូចលោកគ្រូប៉ាយទេ ។

យាយស៊ុំអស់សំណើច ហា! ហា! ឯកាស៊ុំគិតតែមិនបាន លួចញញឹមដៃ ៗ ដូនចាស់ពោលថា:

–ប៉ាយវ៉ាន់ជានធ្លាគណាស់ហើយសន្ធាតទៀតផង, វាហាត់រៀនគុនពីតូចមកជាងម្ភៃឆ្នាំហើយ ឯងទើបនឹងមើលគេមួយយប់សោះ ចង់ខ្លាំងពូកែដូចគេ គេសើចស្លាប់ហើយ ! **(នៅមានត)**

ដំកល់ទុកតាមលេខ ៣២៦ ចុះថ្ងៃទី ២៧-៩-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers